# ចចក និង រាជសីហ៍

តម្រាកម្រើកចិត្ត អាងឥទ្ធិឫទ្ធិឥតវិញ្ញាណ ជាគ្រានោះមែនមាន សត្វចចកមួយអប្រិយ។
នៅក្នុងគុហាស្ងាត់ អាស្រ័យសត្វជាចំណី ដោយសារសត្វរាជសីហ៍ ជាមិត្រភក្តិស្ម័គ្រស្មាគម។
ថ្ងៃមួយចចកចរ ឡើងសិង្ហរចូលល្អាងភ្នំ យល់ថ្មដាមួយធំ ភ្លឺដូចឋានកញ្ចក់ធ្លុះ។
ចចកយល់ឆាយា នៃអាត្មានៅក្នុងនោះ ដឹងជាស្រមោលច្នោះ កើតក្ងួចចិត្តគិតទ្រុស្តមិត្រ។
គិតជាទៅមុសា ប្រាប់សីហាប្រកបឫទ្ធិ ជាមានបច្ចាមិត្រ ចង់ល្បងឫទ្ធិអំណាចពល។
មិត្រអញកាន់មានះ អាងតបះកំហែងហល់ តែជាបញ្ញាទាល់ យល់ស្រមោលគង់បោលដាក់។
មែនបើមិត្រប្រហារ ត្រូវថ្មដានោះជៀងដាក់ គល់កមិត្រគង់បាក់ សូន្យជីវិតពិតពុំខាន។
ជាបើរាជសីហ៍ស្លាប់ សាច់ជាភ័ព្វអញឯងបាន អាស្រ័យទទួលទាន ឃើញជាមានរសឱជា។
ចចកគិតច្នោះហើយ ពុំលង់ឡើយក៏យាត្រា ទៅប្រាប់រាជសីហា ដល់ហើយថាហែមហាមិត្រ។
ឥឡូវមានរាជសីហ៍ មួយនៅទីល្អាងវិចិត្រ អួតថាខ្លួនប្រសិទ្ធិ ចង់ល្បងឫទ្ធិនឹងមិត្រឯង។
រាជសីហ៍ស្តាប់ចចក និយាយឡកដោយកលលេង ស្មានពិតដូចពាក្យថ្លែង កើតជឿចិត្តឥតសង្ស័យ។
ទើបតបថាអើចៅ មកយើងទៅជំនាញជ័យ ខ្លាចអ្វីអាសត្វព្រៃ នៅឯណាណាំចចក។
ចចកនាំរាជសីហ៍ ឡើងគិរីកាត់ឈូងឆក ដរាបទៅដល់ច្រក ល្អាងសិលាថ្មដាធ្លុះ។
ចចកធ្វើជាខ្លាច មកពួនក្រោយរាជសីហ៍ស្មោះ ខ្សឹបថាហ្នុំអីនុះ មិត្រមើលចុះវានោះហើយ។
វាគ្មានព្រឹមមិត្រទេ ឈរចំអែនៅកន្តើយ បើមិត្រធ្វើម្តេចហើយ វាក៏ធ្វើតបវិញស្តែង។
រាជសីហ៍ជឿស្លុះចូល យល់ស្រមោលអាត្មាឯង ស្មានសត្វដទៃផ្សេង ទើបសម្តែងឫទ្ធិសីហា។
ស្ទុះក្រាបចាក់ក្រាញក្រោយ កន្ទុយកោយកន្ទុះរ៉ា សម្រេញញាក់ភក្ត្រា ធ្វើកិរិយាចូលជាញជ័យ។
រូបភាពស្រមោលនោះ ខ្លួនធ្វើច្នោះវាច្នោះនៃ រាជសីហ៍ទោសោក្រៃ ស្ទុះទះទល់ជល់ថ្មដា។
លុះត្រូវសិលាឡាក់ កក៏បាក់ដល់ពិការ រាជសីហ៍សូន្យសង្ខារ នៅនាកាលនោះឯងនៃ។
អនិច្ចាសត្វសីហោ ភ្លើងទោសោដុតឱ្យក្ស័យ មោហោបញ្ញាខ័យ ជំនាញជ័យនឹងរូបឯង។
លុះដល់វិនាសប្រាណ នេះព្រោះគ្មានបញ្ញាឈ្វេង យកតែមានះឯង មកសម្តែងតាំងជាមុខ។
មានះនេះខូចខ្លួន ចុះក្នុងក្បួនលោកតាំងទុក មានះនេះបុករុក នាំមនោឱ្យម្នេញអើយ។





សម្រង់ចាកនិទាន គតិលោក
រៀបរៀងដោយ ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ